## ព្រះរាជាណាចក្រកម្ពុជា
### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ២៣១០ អយក.ជាវ

ថ្ងៃព្រហស្បតិ៍ ១១កើត ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០២៤

**ជម្រាបជូន**

**-ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គាធិការ**
**-ឯកឧត្តម លោកជំទាវ លោក លោកស្រីប្រធានអង្គភាពថ្នាក់កណ្ដាល**
**-លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ ៖** ពង្រឹងនិងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS)លើមុខងារដែលបានដាក់ឱ្យអនុវត្តជាផ្លូវការ ចាប់ពីពេលនេះតទៅ។

**យោង ៖** លិខិតលេខ២៤០៣ អយក.ហវ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ របស់ក្រសួងអប់រំ យុវជន និងកីឡា។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប ឯកឧត្តម លោកជំទាវ លោក លោកស្រី ជ្រាបថាៈ កាលពីឆ្នាំ២០២២ កន្លងមក ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារវិភាជន៍ថវិកា(BA) បញ្ជាទិញ(PO) គណនីត្រូវសង(AP) និងរបាយការណ៍ ដែលមានលក្ខណៈជា Web Application(Online) ជូនអង្គភាពថ្នាក់រដ្ឋបាលកណ្ដាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត តាមស្មារតីនៃលិខិតលេខ២៤០៣ អយក.ហវ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២២ ក្នុងគោលបំណងចូលរួមលើកកម្ពស់សុខុមាលភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយគណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព និងភាពទាន់ពេលវេលា ព្រមទាំងជួយសម្រួលការងារជាអតិបរមាជូនមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុ។

ក្នុងន័យនេះ ក្រសួងបានពិនិត្យឃើញថា អង្គភាពមួយចំនួនធំបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS) លើមុខងារដែលបានដាក់ឱ្យអនុវត្ត បានប្រើប្រាស់យ៉ាងខ្ជាប់ខ្ជួនសម្រាប់ប្រតិបត្តិការជាក់ស្តែង ហើយផ្តោតសំខាន់លើស្ថានភាពនៃការអនុវត្តថវិកា តាមដានការអនុវត្តផែនការសកម្មភាព និងរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងគណនេយ្យ ប្រកបដោយស្មារតីយកចិត្តទុកដាក់ខ្ពស់។ ដោយឡែក ក៏មានអង្គភាពខ្លះនៅថ្នាក់រដ្ឋបាលកណ្ដាល និងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត កង្វះភាពទំនួលខុសត្រូវនិងកិច្ចសហការលើការប្រើប្រាស់ប្រព័ន្ធ EFMS ឱ្យមាននិរន្តរភាព ព្រមទាំងការបញ្ចូលទិន្នន័យមិនមានសង្គតិភាព



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ទៅនឹងការអនុវត្តថវិកាជាក់ស្តែងរបស់អង្គភាពសាមី ជាហេតុធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មរបស់ក្រសួង ជាពិសេសគឺការបញ្ជូនរបាយការណ៍ទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមិនទាន់ពេលវេលាផងដែរ។ ដូចនេះ ក្រសួងចាំបាច់ ត្រូវពង្រឹងនិងជំរុញការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុក្រសួងអប់រំ យុវជន និងកីឡា(EFMS)លើមុខងារដែលបានដាក់ឱ្យប្រើប្រាស់ឱ្យបានទូលំទូលាយនិងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីពេលនេះតទៅ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាពមេត្តាជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "

-កាលប្បវត្តិ
-ឯកសារ .នា. ហិរញ្ញវត្ថុ